# រដ្ឋលេខាធិការ

ជូនចំពោះបងប្អូនដែលរស់នៅរដ្ឋ California

ការបោះឆ្នោតដោយសេរី និងយុត្តិធម៌គឺជាមូលដ្ឋានគ្រឹះ នៃលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសអាមេរិក។ នៅក្នុងប្រវត្តិសាស្ត្រនៃជាតិយើងទាំងមូល យើងធ្លាប់បានរៀបចំការ បោះឆ្នោតក្នុងអំឡុងពេលមានសន្តិភាព និងពេលមានសង្គ្រាមក្នុងអំឡុងពេលសេដ្ឋកិច្ចល្អ និងក្នុងពេលមានវិបត្តិសេដ្ឋកិច្ច និង សូម្បីតែមុនពេលមានជំងឺរាតត្បាត។

ក្នុងឆ្នាំ 2020 មន្ត្រីរៀបចំការបោះឆ្នោតរដ្ឋ California កំពុងខិតខំដោះស្រាយបញ្ហាប្រឈមដោយសារជំងឺ COVID-19។

- អ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះ រួចនឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រ។
- អ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះ រួចអាចចុះឈ្មោះដើម្បីទទួលបានការតាមដានសន្លឹកឆ្នោតបោះតាមសំបុត្រតាមរយៈសារជាអក្សរ (SMS) អ៊ីម៉ែល ឬ ការហៅទូរស័ព្ទជាសំឡេង។
- វិធីសាស្ត្រអនាម័យបន្ថែមនិងវិធានការរក្សា គម្លាតពីគ្នានឹងយកមកប្រើប្រាស់ នៅតាមទីតាំងបោះឆ្នោតទាំងអស់។

អ្នកអាចមើល *vote.ca.gov* សម្រាប់ព័ត៌មាននិងឧបករណ៍មានប្រយោជន៍ បន្ថែមទៀតសម្រាប់ការបោះឆ្នោតនៅឆ្នាំនេះ។

ប្រសិនបើអ្នកមានសំណួរណាមួយ អំពីការចុះឈ្មោះ ឬ ការបោះឆ្នោតរបស់អ្នកនៅសរទរដូវនេះ អ្នកអាចទាក់ទងទៅការិយាល័យរបស់រដ្ឋលេខាធិការតាម ទូរសព្ទឥតគិតថ្លៃ **(888) 345-4917**។

ក្នុងនាមជារដ្ឋលេខាធិការបេសកកម្មរបស់ខ្ញុំ គឺដើម្បីជួយដល់ពលរដ្ឋគ្រប់រូបឲ្យបោះឆ្នោតបាន ប្រកបដោយសុវត្ថិភាពនិងសន្តិសុខ - ប៉ុន្តែខ្ញុំត្រូវការជំនួយពីអ្នកទាំងអស់គ្នា។

ដោយសារជំងឺ COVID-19 ដូច្នេះអាចនឹងមានទីតាំងបោះឆ្នោតដោយ ផ្ទាល់តិចជាងធម្មតានៅក្នុងខោនធីរបស់អ្នក។ អ្នកអាចជួយសហគមន៍របស់អ្នក ដោយការបោះឆ្នោតឲ្យបានមុនក្នុងឆ្នាំនេះ តាម រយៈសំបុត្រ ឬ ទៅដោយផ្ទាល់។ ហ្វូងមនុស្សតិចតួច និងការតម្រង់ជួរខ្លីនៅថ្ងៃបោះឆ្នោត នឹងជួយ ឲ្យមន្ត្រីបោះឆ្នោតរក្សាបានទីតាំងបោះឆ្នោត ដែលមានផាសុកភាពល្អ និងអនុញ្ញាតឲ្យបុគ្គលិកបោះឆ្នោតកាន់តែងាយបម្រើការជូនអ្នកបោះឆ្នោត ដែលត្រូវការជំនួយ — រួមមានអ្នកជិតខាងយើងដែលជាជនពិការអ្នក ដែលត្រូវការជំនួយផ្នែកភាសា ឬ អ្នកដែលត្រូវការសន្លឹកឆ្នោតជំនួស។

សូមធ្វើផែនការឥឡូវនេះសម្រាប់ការបោះឆ្នោតរបស់អ្នកនៅសរទរដូវនេះ។
ការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដូចជារូបអ្នកគឺជាអ្វី ដែលធ្វើឲ្យលទ្ធិប្រជាធិបតេយ្យរបស់យើងពិតជាមានភាព រឹងមាំ។